# ព្រហ្មលិខិត

(បទពាក្យ៨)

ទង្វើលើលោកសោកសៅសុខសាន្ត
ជូនទុក្ខរំខានជូនបានសប្បាយ
អ្នកខ្លះឈឺចាប់ទុក្ខហួសបរិយាយ
ខ្លះសើចក្អាកក្អាយសុខពេញហប្ញទ័យ។

ជួបទុក្ខក្រៀមក្រំសណ្ដំដួងចិត្ត
ខឹងព្រហ្មលិខិតថាឥតប្រណី
អយុត្តិធម៌សាមាន្យអប្រិយ
ដាក់ទណ្ឌទោសពៃរ៍អោយគេទុក្ខា។

អំពើទាំងឡាយកាយដែលគេប្រព្រឹត្ត
បែរជាមិនគិតបន្ទោសកាយា
ទៅដាក់កំហុសបំផ្លើសទោសា
"ឱ!អនិច្ចាព្រហ្មលិខិតអើយ"។

តាមពិតគេភ្លេចឈ្លេចរកយល់ន័យ
ត្រឹមត្រូវប្រពៃមកជាចំលើយ
បើព្រហ្មលិខិតកម្រិតមកហើយ
គ្មាននរណាឡើយប្រឆាំងដំណើរ។

អ្នកដែលតាក់តែងថែង"ព្រហ្មលិខិត"
អ្នកនោះគឺពិតរូបយើងទេតើ
ព្រោះពាក្យប្រែថា"កំណត់ប្រសើរ"
ចេញពីទង្វើជនគ្រប់អង្គា។

អំពើនៃខ្លួនជាអ្នកកំណត់
ចាត់ថែងបែងបទមិនដែលឃ្លាតឃ្លា
បវរឫស្យាចំណារជាប់ជា
គំនូសវាសវារអន្ទោលតាមប្រាណ។

ពុំមែនគំនូសឥន្ទព្រហ្មទេវតា
កំណត់ថែងចារពីសួគ៌ាស្ថាន
តែជាចំណារដែលយើងគ្រប់ប្រាណ
សាងជាលំអានសុខទុក្ខជាក់ស្ដែង។

ពាក្យ"ព្រហ្មលិខិត""កំណត់ប្រសើរ"
គឺមនុស្សទេតើកំណត់ខ្លួនឯង
យុត្តិធម៌ណាស់ពុំមានក្លាយក្លែង
សុខទុក្ខចំបែងថែងតាមទង្វើ។✍

*(២៦ តុលា ២០០២)*

ភិក្ខុ ស្វាត សាលឿម